00211933

ឯកសារ D97/II

នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| កាលបរិច្ឆេទនៃឯកសារ | : | ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | : | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |
| ប្រភេទឯកសារ | : | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11/AUG/2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.FRY

## ចម្លើយតបរបស់ សហព្រះរាជអាជ្ញា
## ទៅនឹងញត្តិស្នើសុំរបស់ អៀង សារី ស្តីពី សហឧក្រិដ្ឋកម្មរួម

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26/03/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fry

**បញ្ជូនដោយ៖**

ការិយាល័យហព្រះរាជអាជ្ញា៖

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉ែត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**ចែកចាយជូន៖**

សហចៅក្រមស៊ើប

ចៅក្រម ប្រាក់ យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

មេធាវីការពារក្តីរបស់ អៀង សារី៖

លោក អាង ឧត្តម

លោក Michael KARNAVAS

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13/AUG/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26/03/2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fry

# ១. សេចក្តីផ្តើម និង សេចក្តីសង្ខេបសំអាងហេតុ

១. នៅក្នុងញត្តិស្នើសុំមួយ ដែលបានដាក់ជូនដោយក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានស្នើសុំសហចៅក្រមស៊ើបអង្កេត កុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (“JCE”) ជាទម្រង់មួយនៃការទទួលខុសត្រូវនៅចំពោះមុខតុលាការនេះ ក្រែងលោវាបញ្ចាំង“ស្រមោលនៃការទទួលខុសត្រូវដ៏ធំមួយ” ទៅលើឥស្សរជនជាន់ខ្ពស់បំផុតផ្នែកនយោបាយ និងផ្នែកយោធារបស់ប្រទេសកម្ពុជាស្ទើរតែទាំងអស់ ដោយរាប់ទាំង លុបចេញ [1] ។ ញត្តិស្នើសុំនោះ បានដាក់ជូនជាច្រើនថ្ងៃមុនពេលដែលសហចៅក្រមស៊ើបអង្កេតត្រូវជ្រើសរើស ទម្រង់នៃការទទួលខុសត្រូវនៅក្នុងសំណុំរឿងដាច់ដោយឡែកមួយ ។

២. ក្រៅពីការស្វែងរកការប្រកាសប្រាប់ដល់មតិសាធារណៈជន និងធ្វើឱ្យនីតិវិធីរបស់តុលាការទៅជានយោបាយ ញត្តិស្នើសុំនោះគឺ៖ ទី១) មានកំហុសផ្នែកនីតិវិធី, ទី២) ស្វែងរកដំណោះស្រាយដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង និងទី៣) សួរអំពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលបានអនុវត្តចាប់តាំងពីតុលាការនៅ Nuremberg តមករហូតដល់ស្ទើរតែគ្រប់តុលាការអន្តរជាតិសំខាន់ៗ ដែលស្រដៀងគ្នានឹងតុលាការនេះដែរ ត្រូវបានគេផ្តល់អាណត្តិឱ្យធ្វើការចោទប្រកាន់ជនទាំងឡាយណាដែលស្ថិតនៅក្នុងតំណែងដឹកនាំផ្នែកនយោបាយ និងផ្នែកយោធា ដែលទទួលខុសត្រូវចំពោះការបំពាន ជារួម និងជាប្រព័ន្ធទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ។ ជាការផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តីដែលថា ការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ថាជាទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនេះនឹង

---

[1] *ករណីរបស់ អៀង សារី,* ពាក្យស្នើសុំរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហកម្មឧក្រិដ្ឋកម្មរួម (JCE), សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៨ កក្កដា ២០០៨, លេខERN 00208225-00208240, D97, ទំព័រទី ១ [*បន្ទាប់ពីនេះទៅហៅថា៖* ញត្តិស្នើសុំ] ។

"*បាចសាច* នូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[2] ដល់បុគ្គលទាំងអស់ខាងលើនេះ ទ្រឹស្តីនេះគ្រាន់តែដាក់ឱ្យមានការទទួលខុសត្រូវលើបុគ្គលទាំងឡាយណា ដែលមានការរួមចំណែក (ផ្ទុយទៅនឹងអ្វីដែលគ្រាន់តែជាការយល់ដឹង) នៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួម ជាមួយនឹងបុគ្គលដទៃ ទៀតជាការសំខាន់នោះគឺបានរួមចំណែកក្នុងការជួយជ្រោមជ្រែងដល់គោលបំណងនោះដោយ មានចេតនាត្រង់ៗដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួន ដែលស្ថិតនៅក្នុងគោលបំណងនោះ[3] ។

៣. សហព្រះរាជអាជ្ញា សន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួម (JCE) គឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលច្បាប់ អ.វ.ត.ក បានអនុញ្ញាត ពីព្រោះវាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិពេញមួយយុត្តាធិការនៃពេលវេលារបស់អង្គជំនុំជម្រះនេះ ។ អាស្រ័យហេតុនេះ ការអនុវត្តន៍នូវទម្រង់នេះនៅចំពោះមុខតុលាការនេះ វាមិនបំពានលើគោលការណ៍៖ *គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)* នោះទេ ។

## ២. ការជំទាស់ដំបូងៗ

*ការពិចារណាហួសពីផ្លូវច្បាប់បានជម្រុញឱ្យមាន ញត្តិស្នើសុំ នេះឡើង*

៤. តាមរយៈការនិយាយឈ្មោះរបស់ឥស្សរៈជននយោបាយទាំងអស់ជាសាធារណៈ ទំនងជាបានប្រឡាក់ប្រឡូសដោយការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ញត្តិស្នើសុំនេះបានស្វែងរកនូវការប្រកាសប្រាប់ដល់មតិសាធារណៈជនថា អាចនឹងមានការលំអៀងទៅខាងការយល់ឃើញរបស់សាធារណៈជនអំពីដំណើរការនីតិវិធីតុលាការសម្រាប់អង្គជំនុំជម្រះនេះ ។ ទីពីរ យ៉ាងហោចណាស់ នៅទំព័រមុខរបស់ញត្តិស្នើសុំនេះ បានស្វែងរកនូវការជះឥទ្ធិពលទៅលើសេចក្តីសម្រេចតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត តាមរយៈការអះអាងថា បើសហចៅក្រមស៊ើបអង្កេត ជ្រើសរើសយកសហកម្មឧក្រិដ្ឋកម្មរួម (JCE) ជាទម្រង់មួយនៃការទទួលខុសត្រូវ នោះៗសហចៅក្រមស៊ើបអង្កេតទំនងជា *នឹងអាចបាចសាចការប្រឡាក់*

---

[2] ញត្តិស្នើសុំ, កថាខណ្ឌទី ៣០ ។

[3] *រដ្ឋអាជ្ញា ទល់នឹង Brdjanin*, សាលដីកា, IT-99-36-A, ចុះថ្ងៃទី០៣ មេសា ២០០៧, កថាខណ្ឌទី ៤៣០ ។

*ប្រឡូស* ទៅលើឥស្សរៈជនជាន់ខ្ពស់ទាំងនោះ ។ ទីបី គោលបំណងដូចជាហួសពីផ្លូវច្បាប់របស់ញត្តិស្នើសុំ ពេលវេលានៃញត្តិស្នើសុំនោះក៏ ទំនងជាមានគោលបំណងជះឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ដែលគេរំពឹងថាខិតជិតមកដល់ការសម្រេចលើបញ្ហានេះ នៅក្នុងសំណុំរឿងមួយដាច់ដោយឡែក ក៏ប៉ុន្តែមានចុងចោទរួម ។ ផ្ទុយទៅវិញ វាជាការណ៍មួយមិនច្បាស់លាស់ទេ ថាហេតុអ្វីបានជាមេធាវីការពារក្តីជ្រើសរើសយកការរង់ចាំជាច្រើនខែ មុននឹងដាក់ជូនញត្តិស្នើសុំនោះ ។ ប៉ុន្តែបើតាមញត្តិស្នើសុំនោះ អ្វីដែលធ្វើឱ្យមានជាញត្តិនោះឡើងគឺ សេចក្តីប្រកាសព័ត៌មានមួយរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧[4] ។

*វិធានដែលបានលើកឡើងនៅក្នុងញត្តិស្នើសុំ មិនអនុញ្ញាតឱ្យមាន ញត្តិស្នើសុំ បែបនេះឡើយ*

៥. គេបានដាក់ជូនញត្តិស្នើសុំនេះតាមវិធាន ៥៣.១ នៃវិធានផ្ទៃក្នុង ("វិធាន") ដែលវិធាននេះមិនអនុញ្ញាតឱ្យមានញត្តិស្នើសុំមួយបែបដូច្នេះទេ ។ វិធាននោះ មានជាប់ទាក់ទងនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយសហព្រះរាជអាជ្ញា ។ វិធាននោះមិនអនុញ្ញាតឱ្យជនត្រូវចោទមានសិទ្ធិជាក់ស្តែង ឬវាទរហិត(មិនមានចែងច្បាស់លាស់) ដើម្បីលើកឡើងជាមួយនឹងសហចៅក្រមស៊ើបអង្កេតលើទឡ្ហីករណ៍ណាមួយឡើយ ។ ហេតុដូច្នេះ ញត្តិស្នើសុំនេះត្រូវបានដាក់ដោយមិនសមស្រប ។

*ញត្តិស្នើសុំ បានស្វែងរកនូវដំណោះស្រាយមួយដែលមិនសមស្រប*

៦. វិធានមិនអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ចេញប្រកាសដំណោះស្រាយទៅតាមច្បាប់ជាធរមាន ឬទម្រង់នៃការទទួលខុសត្រូវណាមួយ ដូចដែលញត្តិនោះបានស្នើសុំនោះទេ ។ នៅពេលដែលវិធាន ចង់ឱ្យអង្គភាពយុត្តិធម៌ណាមួយធ្វើសេចក្តីសម្រេចតាម ច្បាប់ជាធរមាន វិធាននោះមានចែងយ៉ាងជាក់លាក់អំពីអំណាចនោះ ។ ឧទាហរណ៍ វិធាន ១០១.៥ ចែងថា អង្គជំនុំជម្រះសាលាដំបូងមានអំណាចដើម្បី "បញ្ជាក់ពី [...] ច្បាប់ជា ធរមាន" ។ វិធាន

[4] ញត្តិស្នើសុំ, ទំព័រទី ១ ។

00211937





៦៧.២ គ្រាន់តែតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់ពី "ការកំណត់ ប្រភេទបទល្មើស" នៃអង្គហេតុជាសារវ័ន្តនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនតែប៉ុណ្ណោះ ។ កិច្ចការនេះ ត្រូវបានកម្រិតឱ្យនៅត្រឹមតែការចោទប្រកាន់ជន ជាប់ចោទណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម និងការកំណត់ពីទម្រង់នៃការទទួលខុសត្រូវ ដែល មាននៅក្នុងច្បាប់ អ.វ.ត.ក ។ កិច្ចការនេះ មិនបានផ្តល់អំណាចដល់ពួកគេឱ្យបញ្ជាក់ពីប្រកាសដំណោះស្រាយនោះទេ ។ ហេតុ ដូច្នេះ ញត្តិស្នើសុំនេះគួរត្រូវបានបដិសេធចោលដោយសារបានស្វែងរកនូវដំណោះស្រាយមួយ ដែល មិនសមស្រប ។

## ៣. សេចក្តីសំអាង

៧. ញត្តិស្នើសុំនេះ ត្រូវតែបដិសេធចោល តាមការជំទាស់ដំបូងៗខាងលើនេះ ។ ទោះជាយ៉ាងនេះ ក៏ដោយ បើសិនជាញត្តិស្នើសុំតម្រូវឱ្យទទួលយកបាននោះ សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត បដិសេធញត្តិស្នើសុំនោះ តាមទម្រង់ដែលសហកម្មឧក្រិដ្ឋកម្មរួម តម្រូវឱ្យអនុវត្តតាមដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ។

៨. ដើម្បីឱ្យទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមួយ អាចប្រើបាននៅចំពោះមុខអង្គជំនុំ ជម្រះនេះ ទម្រង់នោះត្រូវតែស្របទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ ៖ ទី១) ទម្រង់នោះត្រូវ តែជាលិខិតុបករណ៍មូលដ្ឋានរបស់អង្គជំនុំជម្រះនេះទោះជា វាទិក(មានចែងច្បាស់លាស់) ឬ វាទារហិតក្តី(មិនមានចែងច្បាស់លាស់),ទី២)ទម្រង់នោះត្រូវតែមាននៅក្នុងច្បាប់ទំនៀមទម្លាប់ អន្តរជាតិដែលត្រូវទៅតាមពេលវេលានោះ, ទី៣) ច្បាប់ដែលបានបញ្ញត្តិឱ្យមានទម្រង់នៃការ ទទួលខុសត្រូវនោះ ត្រូវតែអាចរកបានយ៉ាងគ្រប់គ្រាន់ដោយចុងចោទ ដែលត្រូវទៅតាមពេល វេលានោះ និងទី៤) ចុងចោទត្រូវតែមានលទ្ធភាពអាចប្រមើលមើលបានថាខ្លួនអាចនឹងត្រូវឱ្យ ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើទាំងឡាយរបស់ខ្លួន[5] ។ សហព្រះរាជអាជ្ញា ពេលនេះ

---

[5] *រដ្ឋអាជ្ញា ទល់នឹង Milutinović និង គូកន* , សេចក្តីសម្រេចលើញត្តិរបស់ Dragoljub Ojdanić ជំទាស់នឹងបញ្ញាយុត្តាធិការ-សហកម្មឧក្រិដ្ឋកម្មរួម (JCE), IT-99-37-AR72, ចុះថ្ងៃទី២១ ឧសភា ២០០៣, កថាខណ្ឌទី ២១ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Milutinović] ។

បានរកឃើញថា លក្ខខណ្ឌនីមួយៗទាំងនេះគឺត្រូវទៅតាមលក្ខណៈនៃសហកម្មឧក្រិដ្ឋកម្មរួម (JCE) ថាជាទម្រង់នៃការទទួលខុសត្រូវជាធរមានមួយនៅចំពោះមុខអង្គជំនុំជម្រះនេះ ។

*ច្បាប់ អ.វ.ត.ក ចែងអំពី សហកម្មឧក្រិដ្ឋកម្មរួម (JCE) ថាជាទម្រង់នៃការទទួលខុសត្រូវមួយដែលមានសុពលភាព*

៩. ញត្តិស្នើសុំនេះ បានពោលអះអាងថា តាមរយៈការដាក់ទម្រង់នេះយ៉ាងជាក់លាក់ឲ្យនៅក្រៅច្បាប់ អ.វ.ត.ក – ដែលជាឯកសារត្រូវបានអនុម័ត បន្ទាប់ពីតុលាការ ICC បានដាក់បញ្ចូលទម្រង់នេះយ៉ាងច្បាស់លាស់នៅក្នុងលក្ខន្តិកៈរបស់ខ្លួន – ការរកឃើញនូវឯកសារដែលបានច្រានចោលសហកម្មឧក្រិដ្ឋកម្មរួម (JCE) របស់អង្គជំនុំជម្រះនេះ ថាជាទម្រង់នៃការទទួលខុសត្រូវមួយ[6] ។ សហព្រះរាជអាជ្ញា ស្នើឲ្យ សហចៅក្រមស៊ើបអង្កេត ច្រានចោលសេចក្ដីសំអាងនេះ ។ សេចក្ដីសំអាងស្រដៀងគ្នា នៅចំពោះមុខតុលាការស្រដៀងគ្នា ត្រូវបានច្រានចោលដោយស្រដៀងគ្នាដែរ[7] ។

១០. មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលណាក៏ដោយដែលជា "ជនសង្ស័យ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជម្រុញក្នុងការរៀបចំផែនការ *ឬការប្រព្រឹត្ត*" ឧក្រិដ្ឋកម្មទាំងឡាយដែលអង្គជំនុំជម្រះនេះអាចផ្ដន្ទាទោសបាន ។ ទម្រង់ទាំងប្រាំនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយចំពោះនេះ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ទាំងឡាយដែលមាននៅក្នុងលក្ខន្តិកៈសម្រាប់តុលាការ ICTY, ICTR និង SCSL ។ តុលាការនីមួយៗទាំងនេះបានសម្រេចថា គេធ្លាប់បានរកឃើញនូវបុគ្គលដែលបាន "ប្រព្រឹត្ត" ឧក្រិដ្ឋកម្មមួយតាមរយៈការចូលរួមរបស់ខ្លួននៅក្នុងករណីដែលខ្លួនបានដឹងអំពីការរៀបចំរួម ឬគោលបំណងរួម[8]។ ឯកសារយោងយ៉ាងច្បាស់លាស់ចំពោះសហកម្ម

---

[6] ញត្តិស្នើសុំ, ទំព័រទី ៦ ។

[7] សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៣, ១៨ ។

[8] *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi*, សាលដីកា, ICTY-2001-64-A, ចុះថ្ងៃទី០៧ កក្កដា ២០០៦, កថាខណ្ឌទី ១៥៨។ *រដ្ឋអាជ្ញា ទល់នឹង Fofana & Kondewa*, សេចក្ដីសម្រេច, សំណុំរឿងលេខ SCSL-04-14-T, ចុះថ្ងៃទី០២ សីហា ២០០៧, កថាខណ្ឌទី ២០៨ ។

ឧក្រិដ្ឋកម្មរួម (JCE) នៅក្នុងលក្ខន្តិកៈ មិនតម្រូវឱ្យតុលាការមួយអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវនោះទេ[9] ។ ដោយសារគេបានអនុម័តច្បាប់ អ.វ.ត.ក នៅក្នុងខែសីហា ឆ្នាំ២០០១ – គឺចំនួនពីរឆ្នាំក្រោយពីការចេញសាលក្រមរបស់តុលាការ ICTY លើករណីរបស់ *Tadić* ដែលបានសម្រេចថាគេធ្លាប់បានរកឃើញនូវបុគ្គលដែលបាន "ប្រព្រឹត្ត" ឧក្រិដ្ឋកម្មមួយតាមរយៈ "ការចូលរួមរបស់ខ្លួននៅក្នុងការណ៍ដែលខ្លួនបានដឹងអំពីការរៀបចំរួម ឬគោលបំណងរួម"[10] – អ្នកព្រាងច្បាប់ អ.វ.ត.ក មានចេតនាយ៉ាងច្បាស់លាស់ដាក់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួម (JCE) នេះទៅក្នុងវិសាលភាពនៃមាត្រា ២៩ ។

១១. ក្នុងការណ៍ដែលឈានដល់នូវសេចក្ដីសម្រេចនោះ *Tadić* បានអានលក្ខន្តិកៈសម្រាប់តុលាការ ICTY ដែលទាក់ទិននឹងប្រធានបទ និងគោលបំណងរបស់លក្ខន្តិកៈនោះ ហើយបានកត់សម្គាល់ធាតុផ្សំចំនួនពីរនៅក្នុងបរិបទនោះគឺ៖ ក) ឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន "មិនមែនលេចចេញមកពីនិន្នាការឧក្រិដ្ឋរបស់បុគ្គលតែម្នាក់នោះទេ ក៏ប៉ុន្តែបង្កើតឡើងឱ្យមានជាឧក្រិដ្ឋភាពរួម" និងខ) ទោះបីជាសមាជិកមួយចំនួននៃក្រុមនោះអាចនឹងប្រព្រឹត្តអំពើឧក្រិដ្ឋដោយផ្ទាល់ក៏ដោយ ក៏"ជាញឹកញាប់ ការចូលរួមចំណែក និងវិភាគទានរបស់សមាជិកដទៃទៀតនៅក្នុងក្រុមនោះ គឺមានសារៈសំខាន់នៅក្នុងការជួយសម្រួលឱ្យមានការប្រព្រឹត្តិបទល្មើសនោះ" ។ ហេតុដូច្នេះហើយ "ជាញឹកញាប់ ស្ថានទម្ងន់ខាងផ្លូវចិត្តគឺមិនមែនតិចទេ ហើយតាមពិតទៅ គឺមិនខុសគ្នាពីអ្វីទៅនឹងស្ថានទម្ងន់ខាងផ្លូវចិត្តរបស់ពួកអ្នកដែលបានប្រព្រឹត្តអំពើទាំងនោះដោយផ្ទាល់ឡើយ"[11] ។

១២. សញ្ញាណដែលថាមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក គ្របដណ្ដប់ទៅលើសហកម្មឧក្រិដ្ឋកម្មរួម (JCE) មិនគ្រាន់តែអាចទាញយោបល់ពីពាក្យសព្ទនៅក្នុងបញ្ញត្តិនោះប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវបានគាំទ្រដោយប្រធានបទ និងគោលបំណងនៃច្បាប់អ.វ.ត.ក ថែមទៀតផង។ មាត្រា ១ នៃច្បាប់

[9] សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ២០ ។

[10] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadić និង គូកន* , សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី15 កក្កដា ១៩៩៩, កថាខណ្ឌទី ១៨៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្ដីសម្រេចលើករណីរបស់ Tadić] ។

[11] សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៤០-៤១ ។

អ.វ.ត.ក ចែងថា ច្បាប់នេះរៀបចំឡើងក្នុង"គោលបំណង"វិនិច្ឆ័យទោស"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបនោះ ។ ភាសានេះ គាំទ្រនូវការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួម (JCE) នៅចំពោះមុខអង្គជំនុំជម្រះនេះ តាមមធ្យោបាយចំនួនពីរយ៉ាង ។

១៣. ទីមួយ ភាសានោះមានលក្ខណៈច្បាស់លាស់ដែលថា អង្គជំនុំជម្រះនេះនឹងកាត់សេចក្ដីពួក "មេដឹកនាំជាន់ខ្ពស់" និងជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" តែប៉ុណ្ណោះចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ នេះជាការសំខាន់ ពីព្រោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងចាប់តាំងពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ជាទូទៅ គឺមិនមែនជាអំពើដាច់ដោយឡែកតែឯងរបស់បុគ្គលជាមន្ត្រីទាំងនោះទេ ក៏ប៉ុន្តែជាលទ្ធផលនៃគោលនយោបាយឧក្រិដ្ឋដោយចេតនា ដែលបានរៀបចំ និងបានអនុវត្តដោយ *ពួកខ្មែរក្រហម*[12] ។ ហេតុដូច្នេះ ដើម្បីធ្វើឱ្យអាណត្តិរបស់ខ្លួនបានសម្រេចជោគជ័យក្នុងការកាត់សេចក្ដីពួក"មេដឹកនាំជាន់ខ្ពស់" និងជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងនោះ វាជាការសំខាន់ណាស់ដែលថា អង្គជំនុំជម្រះនេះត្រូវមានលទ្ធភាពដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅលើបុគ្គលទាំងឡាយណាដែលបានបង្កើត និងតាមដានការអនុវត្តន៍គោលនយោបាយឧក្រិដ្ឋរបស់ពួកខ្មែរក្រហម ដែលជាការផ្ទុយទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងតាមដានគោលនយោបាយទាំងនោះដោយបុគ្គលខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ[13] ។

១៤. ទីពីរ ការបកស្រាយមាត្រា ២៩ ដោយមានការរាប់បញ្ចូលនូវសហកម្មឧក្រិដ្ឋកម្មរួម (JCE) គឺមានសារៈសំខាន់ណាស់ចំពោះការកាត់សេចក្ដីមួយដ៏មានប្រសិទ្ធិភាព លើឧក្រិដ្ឋកម្មអន្តរជាតិដែលមានទំហំដ៏ធំធេងកំពុងស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះនេះ ។ ដូចដែលបានពន្យល់ក្នុងករណីរបស់*Tadić* ឧក្រិដ្ឋកម្មអន្តរជាតិភាគច្រើនត្រូវបានប្រព្រឹត្តដោយក្រុមបុគ្គលដែលបានធ្វើតាមផែនការឧក្រិដ្ឋរួម។ ហេតុដូច្នេះ ទោះបីជាមានតែសមាជិកមួយចំនួនដែល

---

[12] របាយការណ៍របស់ក្រុមអ្នកជំនាញការសម្រាប់ការស្ដាបនាប្រទេសកម្ពុជាឡើងវិញ តាមសេចក្ដីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៣៥, កថាខណ្ឌទី ៦, ១៥ [*បន្ទាប់ពីនេះទៅហៅថា៖* របាយការណ៍របស់ក្រុមអ្នកជំនាញការ អ.ស.ប] ។

[13] សេចក្ដីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៩០ ។

អាចប្រព្រឹត្តអំពើឧក្រិដ្ឋដោយផ្ទាល់ក្តី ក៏ការចូលរួមចំណែក និងវិភាគទានរបស់អ្នកដទៃទៀតជាញឹកញាប់ គឺមានសារៈសំខាន់នៅក្នុងការជួយសម្រួលឲ្យមានការប្រព្រឹត្តិបទល្មើសនោះមានន័យថា ស្ថានភាពទម្ងន់ខាងផ្លូវចិត្តនៃការចូលរួមចំណែកបែបនោះ គឺមិនខុសគ្នាពីអ្វីទៅនឹងស្ថានភាពទម្ងន់ខាងផ្លូវចិត្តរបស់ពួកអ្នកដែលបានប្រព្រឹត្តអំពើទាំងនោះដោយផ្ទាល់ឡើយ" ។

១៥. ច្បាប់ អ.វ.ត.ក - ដូចច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌពិសេសដទៃទៀតដែរ បានកំណត់ត្រឹមតែក្របខ័ណ្ឌដែលតុលាការនេះអាចប្រើប្រាស់បាននូវយុត្តាធិការរបស់ខ្លួន[14] តែប៉ុណ្ណោះ ។ ហេតុដូចនេះ សេចក្តីយោងមួយទៅលើទម្រង់ណាមួយនៃការទទួលខុសត្រូវ មិនចាំបាច់មានចែងច្បាស់លាស់នៅក្នុងក្របខណ្ឌនោះឡើយ ដើម្បីឲ្យវាស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ[15] ។ ច្បាប់ អ.វ.ត.ក ដូចគ្នានឹងច្បាប់លក្ខន្តិកៈរបស់ ICTY ដែរ វាមិនមែន ហើយក៏មិនបានអះអាងថាជា ក្រុមមួយដែលមានលក្ខណៈពិស្តារល្អិតល្អន់ ដែលចែងច្បាស់លាស់សំរាប់គ្រប់ទិដ្ឋភាពដែលអាចមាននិងគ្រប់ដំណោះស្រាយទាំងអស់ដែលអាចមាននៅក្នុងនោះឡើយ[16] ដែលនេះវា មិនដូចគ្នាទៅនឹងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមទេ ។ ជាការបន្ថែម និងទៅតាមទម្រង់របស់វា មាត្រា ២៩ នៃច្បាប់អ.វ.ត.ក បើតាមលក្ខណៈរបស់វាមិនមានការរៀបរាប់អស់ទេ ដោយសារការប្រើឃ្លាថា "ឬ ការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[17] ។ ញត្តិស្នើសុំនោះ ក៏មិនជំទាស់ថាទម្រង់នៃការទទួលខុសត្រូវ មានទាំងអស់គ្មានចន្លោះនោះដែរ ។

១៦. ដោយបានផ្អែកទៅលើចរិតលក្ខណៈនៃសហកម្មឧក្រិដ្ឋកម្មដោយភាន់ច្រឡំ ញត្តិស្នើសុំតវ៉ាថា "ជនទាំងឡាយណា [ដូចបុគ្គលលក្ខណៈនយោបាយ ដែលបានរៀបរាប់ឈ្មោះនៅក្នុងញត្តិស្នើសុំ] ដែលអនុវត្ត ឬប្រើប្រាស់ឥទ្ធិពលនៅក្នុងពេលដែលពាក់ព័ន្ធ" អាចនឹងត្រូវគេមើលឃើញថាជាសហចារីដែលមិនទាន់ត្រូវបានចោទប្រកាន់[18] ។ ការអះអាងនេះគួរតែត្រូវបានបដិសេធ ។ សហកម្មឧក្រិដ្ឋកម្ម គឺខុសគ្នាពីសមាជិកភាពនៃសហកម្មឧក្រិដ្ឋកម្ម (ទោះបីសមាជិកណាម្នាក់

[14] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៨ ។

[15] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៨ ។

[16] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៨ ។

[17] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៩ ។

[18] ញត្តិស្នើសុំ, កថាខណ្ឌទី ៣២ ។

អនុវត្ត ឬប្រើប្រាស់ឥទ្ធិពលនៅក្នុងក្រុមក៏ដោយ)[19] ។ សមាជិកភាពនៃសហាកម្មឧក្រិដ្ឋកម្ម ត្រូវបានគេចោទប្រកាន់ខាងផ្នែកព្រហ្មទណ្ឌជាបទល្មើសដាច់ដោយឡែក នៅក្នុងសវនាការជំនុំជម្រះ នៅនូរ៉ាំប៊ឺក និងនៅក្នុងសវនាការដទៃទៀតជាបន្តបន្ទាប់[20] ។ ច្បាប់ អ.វ.ត.ក មិនបានរាប់បញ្ចូលបទល្មើសណាមួយដូច្នេះទេ ។ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយអនុលោមទៅតាមសហាកម្មឧក្រិដ្ឋកម្មរួមមួយ មិនមែនជាការទទួលខុសត្រូវសំរាប់សមាជិកភាពតែមួយប៉ុណ្ណោះទេ ឬសំរាប់ការសមគំនិតដើម្បីប្រព្រឹត្តបទឧក្រិដ្ឋដែរ ប៉ុន្តែវាទាក់ទងនឹង *ការចូលរួម* នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលជាផ្នែកនៃសហាកម្មឧក្រិដ្ឋកម្មរួមមួយ[21] ។

១៧. ញត្តិស្នើសុំសន្និដ្ឋានថា សហាកម្មឧក្រិដ្ឋកម្មរួម មិនអនុវត្តនៅចំពោះមុខតុលាការនេះទេ ព្រោះវាមិនមែនជាផ្នែកមួយនៃច្បាប់កម្ពុជា[22] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅពេលដែល សហាកម្មឧក្រិដ្ឋកម្មរួម មានចែងកំណត់រួចហើយនៅក្នុងច្បាប់អ.វ.ត.ក វាមិនចាំបាច់មាននៅក្រោមច្បាប់កម្ពុជាទេ ។ ក្នុងនាមតុលាការដែលមានចរិតលក្ខណៈអន្តរជាតិពិសេស ដែលជាប់កាតព្វកិច្ចតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទម្រង់នៃការទទួលខុសត្រូវក្នុងស្រុក មិនត្រូវយកមកអនុវត្តទាក់ទិននឹងបទឧក្រិដ្ឋអន្តរជាតិ នៅចំពោះមុខតុលាការនេះឡើយ ។ តុលាការនេះ គឺជាស្ថាប័នកាត់ក្តីខុសប្លែកពីគេ ដែលស្ថិតនៅក្រោមវិធាន និងនីតិវិធីជាក់លាក់ ហើយក៏មិនមែនជាផ្នែកមួយនៃឋានានុក្រមនៃតុលាការកម្ពុជានោះដែរ[23] ។ ក្នុងករណី *ឌុច* អង្គបុរេជំនុំជម្រះបានលើកយកសញ្ញាបង្ហាញ (indicia) មួយចំនួនរបស់តុលាការអន្តរជាតិមួយ - រួមទាំងបាននិយាយថា វាជា "ការសំដែងឆន្ទៈរបស់សហគមន៍អន្តរជាតិ" ដែលជាផ្នែកមួយនៃ "យន្តការស្វែងរកយុត្តិធម៌អន្តរជាតិ" ហើយមានយុត្តាធិការ "ក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់

---

[19] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ២៥ ។

[20] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ២៥ ។

[21] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ២៦ ។

[22] ញត្តិស្នើសុំ, ទំព័រទី ១ ។

[23] *ករណីរបស់ កាំង ហ្គេកអ៊ាវ*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០១) ចុះថ្ងៃទី០៣ ធ្នូ ២០០៧ កថាខណ្ឌទី ១៨-២០ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច] ។

ធូរ"[24] ។ អាស្រ័យហេតុនេះ អត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្រោមច្បាប់កម្ពុជា គឺវាមិនពាក់ព័ន្ធគ្នាទេ សំរាប់ការអនុវត្តន៍នៅចំពោះមុខតុលាការនេះ ។

*សហកម្មឧក្រិដ្ឋកម្មរួម មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩*

១៨. ញត្តិស្នើសុំសន្និដ្ឋានថា (១) សហកម្មឧក្រិដ្ឋកម្មរួម មិនត្រូវបានទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង(២) ហើយបើទោះបីជាត្រូវបានទទួលស្គាល់នាពេលបច្ចុប្បន្ន ក៏វាមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩ ដែរ និង(៣) ហើយវាក៏មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអនុវត្តដោយផ្ទាល់ដោយតុលាការកម្ពុជា ដែរ[25] ។ សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត ច្រានចោលសេចក្តីសំអាងនេះ ។

១៩. ករណី *Tadić* បានសន្និដ្ឋានចុងក្រោយថា សញ្ញាណនៃការធ្វើសកម្មភាពស្របតាមបំណងរួម ឬការចូលរួមនៅក្នុង សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំថាជា ទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[26] និងនៅក្នុងច្បាប់លក្ខន្តិកៈរបស់ ICTY[27] ដូចបាននិយាយពីខាងលើ ។ គេសម្រេចបានការសន្និដ្ឋានដូចនេះដោយការពឹងផ្អែកទៅលើកម្មវត្ថុ និងគោលបំណងនៃច្បាប់លក្ខន្តិកៈ[28] ដែលថា "ប្រភេទពិតប្រាកដនៃឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន ដែលបានប្រព្រឹត្តឡើងក្នុងលក្ខណៈធម្មតាបំផុតមួយ នៅក្នុងស្ថានភាពនៃពេលសង្គ្រាម"[29] ដែលជាការពិនិត្យឡើងវិញដ៏ទូលំទូលាយមួយនៅលើករណីយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី II[30] ដោយមានឧទាហរណ៍ខ្លះអំពីលិខិតុបករណ៍

---

[24] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨-២០ ។

[25] ញត្តិស្នើសុំ ទំព័រទី ១ ។

[26] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២០, ២២៦ ។

[27] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៩០-១៩៥, ២២០, ២២៦-២២៨ ។

[28] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៨៩, ១៩១ ។

[29] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៩១ ។

[30] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២១-២២២ ។

អន្តរជាតិ[31] និងការសិក្សាប្រៀបធៀបនៅលើផ្នែកច្បាប់របស់ប្រទេសអូស្ត្រាលី កាណាដា អង់គ្លេសនិងវេល បារាំង អាល្លឺម៉ង់ អ៊ីតាលី ហូឡង់ សហរដ្ឋអាមេរិក និងហ្សាំប៊ី[32] ។

២០. ករណី *Tadić* បានរកឃើញថា ខណៈដែលនីតិកម្ម និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី II មិនបាននិយាយសំដៅចំៗទៅលើ "សហកម្មឧក្រិដ្ឋកម្មរួម" ក៏ដោយ ក៏គំនិតនៃ "បំណងរួម", "ផែនការរួម" ដែលគេបានប្រើនៅទីនោះ គឺជាពាក្យដែលមានន័យដូចគ្នាជាមួយនឹងពាក្យថា សហកម្មឧក្រិដ្ឋកម្មរួម នេះឯង[33] ។

២១. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការរកឃើញនៅក្នុងករណី *Tadić* ដែលថា សហកម្មឧក្រិដ្ឋកម្មរួម បានចាក់ឫសនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៩២ - ក៏អនុវត្តចំពោះបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តិក្នុងរវាងឆ្នាំ ១៩៧៥-១៩៧៩ ផងដែរ ។ នេះក៏ដោយសារមានភស្តុតាងបង្ហាញតាមរយៈការសើរើឡើងវិញមួយ នៅលើទម្រង់នៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម ដែលបានបំរើឲ្យការចោទប្រកាន់នៃឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ តាំងពីសង្គ្រាមលោកលើកទី II មក ។

២២. សញ្ញាណដែលថា បុគ្គលសមាជិកម្នាក់នៃផែនការរួម អាចនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះអំពើព្រហ្មទណ្ឌដែលបានប្រព្រឹត្តឡើងដោយអ្នកចូលរួមជាសហសេវិក នៅក្នុងការប្រតិបត្តិនូវផែនការ ដែលត្រូវបានដាក់បញ្ចូលជាក្រមនៅក្នុងឯកសារច្បាប់ជាសារវ័ន្តចំនួនបី ចាប់ពីក្រោយសម័យសង្គ្រាម៖ ធម្មនុញ្ញទីក្រុងឡុងនៃតុលាការយោធាអន្តរជាតិ ("ធម្មនុញ្ញ IMT")[34] ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ ("ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា")[35] និងធម្មនុញ្ញនៃតុលាការយោធា

---

[31] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២១-២២២ ។

[32] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៣-២២៤ ។

[33] សេចក្តីសម្រេចលើករណីរបស់ Milutinović, មតិដាច់ដោយឡែករបស់ចៅក្រម David Hunt, កថាខណ្ឌទី ៥ ។ សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៦ ។

[34] ធម្មនុញ្ញទីក្រុងឡុងនៃតុលាការយោធាអន្តរជាតិ, មាត្រា ៦ [*បន្ទាប់ពីនេះទៅហៅថា៖* ធម្មនុញ្ញ IMT] ។

[35] ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ *នៅក្នុងរដ្ឋកិច្ចផ្លូវការនៃក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអាល្លឺម៉ង់* (១៩៤៦), ភាគទី ៣ ទំព័រទី ៥០ [*បន្ទាប់ពី នេះទៅហៅថា៖* ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា] ។

អន្តរជាតិសំរាប់ចុងបូព៌ា[36] ។ ធម្មនុញ្ញ IMT មិនបានប្រើឃ្លាថា"សហកម្មឧក្រិដ្ឋកម្មរួម" ទេ ប៉ុន្តែបាន យោងសំដៅទៅដល់ការចូលរួមរបស់ចុងចោទនៅក្នុង"ផែនការរួម ឬការសមគំនិត" ។ បើនិយាយឲ្យចំទៅ គេបានចោទប្រកាន់បទព្រហ្មទណ្ឌលើការចូលរួមនៅក្នុង "ផែនការរួម ឬការសម គំនិត" ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព[37] ។ ធម្មនុញ្ញនេះបានចែងថា "ជនណាដែលបានចូលរួមនៅក្នុងផែនការរួម ឬការសមគំនិតដើម្បីប្រព្រឹត្តិបទឧក្រិដ្ឋ *ណាមួយ* ដែលមានចែងនៅក្នុងធម្មនុញ្ញនេះ ត្រូវទទួលខុសត្រូវ *រាល់អំពើទាំងអស់* ដែលកើតចេញពីការប្រតិបត្តិផែនការរួម ឬការសមគំនិតនោះ ។

២៣. ទោះបី ធម្មនុញ្ញ IMT បានធ្វើការកាត់សេចក្តីតែមេដឹកនាំជាន់ខ្ពស់របស់ ណាស៊ី តែម្តងប្អូននាក់ក៏ដោយ ក៏អំណាចកាន់កាប់ដែលបានអនុម័តច្បាប់គ្រប់គ្រងក្រុមប្រឹក្សា បានផ្តល់អំណាចឲ្យពួកគេធ្វើការកាត់សេចក្តីជនសង្ស័យចំពោះបទឧក្រិដ្ឋបន្ថែមទៀតបាន នៅក្នុងតំបន់កាន់កាប់របស់ពួកគេ ។ មាត្រា ២ នៃច្បាប់ខាងលើនេះ បានចែងថា "ជនណា ដោយមិនគិតពី [...] សមត្ថភាពដែលជននោះបានប្រព្រឹត្ត នឹងត្រូវបានចាត់ទុកថា បានប្រព្រឹត្តបទឧក្រិដ្ឋ [...] ប្រសិនបើ ជននោះមានការជាប់ទាក់ទិនទៅនឹងផែនការ ឬសហកម្មទាំងឡាយណា ដែលកំពុងតែមានការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទល្មើសនោះ" ។

២៤. សវនាការជំនុំជម្រះក្តីស្របតាមធម្មនុញ្ញ IMT និងសវនាការជំនុំជម្រះក្តីដទៃទៀតដែលបានធ្វើឡើងអនុលោមទៅតាមច្បាប់គ្រប់គ្រងក្រុមប្រឹក្សា តំណាងឲ្យតែមួយចំណែកប៉ុណ្ណោះនៃករណីនានាដែលបាននាំមកកាន់ការជំនុំជម្រះក្តី នៅក្នុងស្ថានការណ៍បន្តបន្ទាប់នៅសម័យកាលក្រោយសង្គ្រាមលោកលើកទី II ។ តាមការពិត ការចោទប្រកាន់ថ្នាក់ជាតិរាប់ពាន់ ក៏បានធ្វើឡើងផងដែរ[38] ។ ប្រភេទនៃករណីនេះ មានការពាក់ព័ន្ធជាពិសេសទៅដល់ការបង្កើតច្បាប់លក្ខន្តិកៈនៃសហកម្មឧក្រិដ្ឋកម្មរួម ក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ ពីព្រោះវារុញថយក្រោយនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ហើយករណី *Tadić* ក្នុងឆ្នាំ១៩៩២ បានពឹងផ្អែក

---

[36] ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសំរាប់ចុងបូព៌ា, មាត្រា ៥ ។

[37] ធម្មនុញ្ញ IMT, មាត្រា ៦ ។

[38] ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, ករណី និងភស្តុតាង, ទំព័រទី ៦៣៤ ។

ទាំងស្រុងទៅលើករណីទាំងអស់នេះ នៅក្នុងការកំណត់អំពីសហកម្មឧក្រិដ្ឋកម្មរួម ថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[39] ។

២៥. គ្រប់ករណីទាំងអស់ដែលបានជំនុំជម្រះនៅតំបន់អង់គ្លេស ដែលបានកាន់កាប់ដោយអាល្លឺម៉ង់ ត្រូវបានកាត់សេចក្តីដោយតុលាការយោធាអង់គ្លេស[40] ។ តាមរយៈសេចក្តីសម្រេចរបស់តុលាការយោធាអង់គ្លេសនេះ គឺវាច្បាស់ណាស់ថា តុលាការអនុវត្តតាមទម្រង់មួយនៃសហកម្មឧក្រិដ្ឋកម្មរួម ។ នៅក្នុងករណី *Essen Lynching*[41] ជនស៊ីវិលចំនួនបីនាក់ដែលត្រូវបានតុលាការកាត់ឱ្យជាប់ទោស "ត្រូវបានរកឃើញថា មានពិរុទ្ធដោយសារពួកគេម្នាក់ៗសុទ្ធតែបានចូលរួមក្នុងទម្រង់មួយ ឬច្រើន នៅក្នុងការធ្វើបាបដែលនាំឱ្យមានការស្លាប់ជនរងគ្រោះជាយថាហេតុ" ទោះបីជា "គ្មានជនជាប់ចោទណាម្នាក់ដែលគេប្រឆាំងជំទាស់ទាំងនោះមិនត្រូវបានគេរកឃើញនូវភស្តុតាងណាមួយអាចបញ្ជាក់ថា ពួកគេម្នាក់ៗបានបាញ់ ឬវាយ ដែលបណ្តាលឱ្យមានការស្លាប់"[42] ក៏ដោយ ។ នៅក្នុងសវនាការជំនុំជម្រះក្តីករណី *Almelo* បានបង្ហាញបន្ថែមពីគំនិតនៃការទទួលខុសត្រូវនៅក្នុង "សហកម្មឧក្រិដ្ឋកម្ម" ដែលបានអនុវត្តដោយតុលាការយោធាអង់គ្លេស[43] ។ នៅក្នុងករណីនោះ ចៅក្រមយោធាបានពន្យល់ថា៖ "ប្រសិនបើមនុស្សទាំងអស់បង្ហាញខ្លួនទាំងអស់គ្នាក្នុងពេលតែមួយ ដោយចូលរួមនៅក្នុងសហកម្មរួមដែលជាអំពើខុសនឹងច្បាប់ ហើយតាមមធ្យោបាយផ្ទាល់ខ្លួន មនុស្សម្នាក់ៗក្នុងចំណោមពួកគេ ជួយ

---

[39] Damner & Martinez, ទំព័រទី ១៧ (ដែលបានយោងនៅក្នុងញត្តិស្នើសុំ កថាខណ្ឌទី ៥) ។

[40] រាជសិទ្ធិ/អនុញ្ញាត (Royal Warrant) - បទបញ្ជាផ្នែកក្នុងសម្រាប់ធ្វើការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម, ០១៦០/២៤៩៨, ចុះថ្ងៃទី១៤ មិថុនា ១៩៤៥, អាចរកមើលបាននៅក្នុងគេហទំព័រ http://www.yale.edu/lawweb/avalon/imt/imtroval.htm ។

[41] *ដោយយោងទៅលើករណីរបស់ Erich Heye និង គូកន*, តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម, Essen (ដែលបានពិភាក្សានៅក្នុងរបាយការណ៍របស់គណៈកម្មការច្បាប់នៃអង្គការសហប្រជាជាតិ១ សម្រាប់ធ្វើការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម, គណៈកម្មការទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ ៨៨ (១៩៤៧) [*បន្ទាប់ពីនេះទៅហៅថា៖* ករណីរបស់ Essen Lynching] ។

[42] ករណីរបស់ Essen Lynching, ទំព័រទី ៩១ ។

[43] *ការជំនុំជម្រះក្តីលើករណីរបស់ករណី Almelo,* ការជំនុំជម្រះក្តីលើករណីរបស់ Otto Sandrock និងជនចំនួន ៣ នាក់ផ្សេងទៀត, តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម (បានពិភាក្សានៅក្នុងរបាយការណ៍ច្បាប់សម្រាប់ជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម, គណៈកម្មការទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ (១៩៤៩) [*បន្ទាប់ពីនេះទៅហៅថា៖* ការជំនុំជម្រះក្តីលើករណីរបស់ Almelo] ។

នៅក្នុងគោលបំណងរួមរបស់មនុស្សទាំងអស់ នោះពួកគេទាំងអស់គ្នាមានពិរុទ្ធស្មើៗគ្នាទៅតាមច្បាប់"[44] ។ នៅក្នុងករណី *Jespen* ទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមខ្លះ ត្រូវបានគេអនុវត្តដើម្បីចាត់តាំងឱ្យមានការទទួលខុសត្រូវទៅលើការធ្វើមនុស្សឃាតលើឈ្លើយសឹក[45]។ នៅក្នុងការសរុបសេចក្តីរបស់ខ្លួន ចៅក្រមយោធាបានសង្កេតឃើញថា៖ "ប្រសិនបើ Jespen បានពាក់ព័ន្ធយ៉ាងសកម្មដោយផ្ទាល់ជាមួយឆ្មាំងទៃទៀត និងបានជួយឆ្មាំទាំងនោះក្នុងការសម្លាប់មិនរើសមុខ នោះអំពើរបស់មនុស្សម្នាក់ៗនៃជនទាំងអស់នោះ បានក្លាយទៅជាអំពើរបស់មនុស្សទាំងអស់គ្នា[46] ។

២៦. តុលាការយោធាអាមេរិកនៅ Dachau ត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមសេចក្តីបង្គាប់ដែលបានបញ្ជាក់នូវពាក្យ"ឧក្រិដ្ឋជន [...] ដោយរាប់បញ្ចូលនូវជនទាំងឡាយដែល [...] ជាប់ទាក់ទិនជាមួយនឹងផែនការ ឬសហកម្មដែលមានការពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិរបស់ពួកគេ[47] ។ ករណី *Borkum Island Case* គឺជាការកាត់សេចក្តីមួយក្នុងចំណោមសវនាការជំនុំជម្រះក្តីនានា ដែលបានធ្វើឡើងដោយតុលាការនេះ[48] ។ ទោះបីមិនមានសាលក្រមណាមួយត្រូវបានគេផ្សព្វផ្សាយក៏ដោយ ក៏អង្គហេតុនានានៃករណីនោះផ្តល់យោបល់ថា ចុងចោទត្រូវបានកាត់ឱ្យជាប់ទោសដោយសារគេបានរកឃើញថា "បានជាប់ទាក់ទិនជាមួយនឹងផែនការ ឬសហកម្ម" ដែលមានការពាក់ព័ន្ធនៅក្នុងការធ្វើមនុស្សឃាតទៅលើឈ្លើយសង្គ្រាម[49]។ នៅក្នុងការជំនុំជម្រះក្តីករណីជំរុំប្រមូលផ្តុំ *Dachau Concentration Camp* តុលាការបានសន្និដ្ឋានជាចុងក្រោយថា "នៅក្នុងជំរុំ មានប្រព័ន្ធជាទូទៅមួយនៃអំពើឃោរឃៅ និងការធ្វើមនុស្ស

---

[44] ការជំនុំជម្រះក្តីលើករណីរបស់ Almelo, ទំព័រទី ៤០ ។

[45] *ករណីរបស់ Gustav Alfred Jespen*, តុលាការយោធាអង់គ្លេស, Luneburg, សេចក្តីសម្រេច, ចុះថ្ងៃទី២៤ សីហា ១៩៤៦, ទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ, ខែមីនា ឆ្នាំ២០០៧, ទំព័រទី ២២៨, [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Jespen] ។

[46] សេចក្តីសម្រេចលើករណីរបស់ Jespen, ទំព័រទី ២២៩ ។

[47] សេចក្តីបង្គាប់ស្តីពីការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យនៃឧក្រិដ្ឋកម្មសង្គ្រាម ឬបទល្មើសផ្សេងទៀត និងការជំនុំជម្រះក្តីជនល្មើសជាក់លាក់, ចុះថ្ងៃទី០៨ កក្កដា ១៩៤៥, ច្បាប់ចម្លងលេខ ២៦ JCS. 1023/10, មាត្រា ៣, អាចរកមើលបាននៅក្នុងគេហទំព័រ http://www.yale.edu/lawweb/avalon/imt/imtjcs.htm [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីបង្គាប់] ។

[48] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២១០ ។

[49] សេចក្តីបង្គាប់, មាត្រា ៣ ។

ឃាតទៅលើអ្នកទោស" ដែល "ប្រព័ន្ធនេះ ត្រូវបានអនុវត្តដោយមានការយល់ដឹងរបស់ជនសង្ស័យដែលពួកគេជាសមាជិកនៃបុគ្គលិក និងដោយមានការចូលរួមយ៉ាងសកម្មពីពួកគេ ហេតុដូច្នេះហើយ បុព្វហេតុនៃអំពើនេះរួមបង្កើតបាននូវ "ការធ្វើសកម្មភាពទៅតាមគំរោងផែនការរួមមួយដើម្បីរំលោភច្បាប់ និងការប្រើប្រាស់នូវសង្គ្រាម"[50] ។ នៅក្នុងករណី *Mauthausen Camp Case*[51] តុលាការយោធាជាន់ខ្ពស់នៃរដ្ឋាភិបាលសហរដ្ឋអាមេរិកបានបង្កើតឱ្យមាន"របកគំហើញពិសេសចំនួនបី"៖(១)ការប្រព្រឹត្តិទៅរបស់ជំរុំគឺជាសហឧក្រិដ្ឋកម្ម (២) មន្ត្រីទាំងអស់នៅក្នុងជំរុំដែលបានបំរើការងារ ឬដែលគ្រាន់តែបង្ហាញខ្លួននៅ ក្នុងជំរុំនៅពេលណាមួយ បានដឹងពីគំរោងផែនការរួម ដែលនោះគឺជាឧក្រិដ្ឋភាពនៃសហកម្មនោះ និង (៣) ដែលមន្ត្រីទាំងអស់ដែលបានចូលរួមពាក់ព័ន្ធនៅក្នុងប្រតិបត្តិការនៃសហកម្មឧក្រិដ្ឋកម្មនេះ "ទោះតាមមធ្យាបាយណាមួយក៏ដោយ" ត្រូវមានពិរុទ្ធអំពីការរំលោភច្បាប់ និងការប្រើប្រាស់សង្គ្រាម"[52] ។

២៧. នៅក្នុងការពិភាក្សាអំពីគ្រឹះនៃការបង្កើតសហកម្មឧក្រិដ្ឋកម្មរួម ករណី *Tadić* បានធ្វើការវិភាគនៅលើករណីនានាមួយឈុតដែលបានសម្រេចដោយតុលាការក្រុងនៃប្រទេសអ៊ីតាលី ដោយប្រើច្បាប់របស់អ៊ីតាលី ។ ឧទាហរណ៍ករណី D'Ottavio[53] តុលាការបានអនុវត្តមាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌអ៊ីតាលីដែលចែងថា "នៅពេលណាក៏ដោយដែលបទឧក្រិដ្ឋបានប្រព្រឹត្តឡើង ដែលមានលក្ខណៈខុសពីឆន្ទៈចង់បានរបស់អ្នកចូលរួមម្នាក់ ក្នុងចំណោមអ្នកចូលរួមទាំងអស់

---

50 *ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau (Dachau Concentration Camp),* ការជំនុំជម្រះក្តីលើករណីរបស់ Martin Gottfried Weiss និងជនចំនួន ៣៩ នាក់ផ្សេងទៀត, តុលាការរដ្ឋាភិបាលយោធាទូទៅនៃតំបន់សហរដ្ឋអាមេរិក (General Military Government Court of the United States Zone), *បោះពុម្ពឡើងវិញនៅក្នុង* របាយការណ៍របស់គណៈកម្មការច្បាប់នៃអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៧, ទំព័រទី ១៤ [*បន្ទាប់ពីនេះទៅហៅថា៖* ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau] ។

51 តុលាការយោធានៃតំបន់សហរដ្ឋអាមេរិក, Dachau, ប្រទេសអាល្លឺម៉ង់, ចុះថ្ងៃទី២៩ មីនា - ១៣ ឧសភា ១៩៤៦ (ដែលបានពិភាក្សានៅក្នុងការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau, ទំព័រទី ១៥-១៦) ។

52 ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau, ទំព័រទី ១៥) ។

53 *ករណីរបស់ D'Ottavio,* សាលាវិនិច្ឆ័យប្រទេសអ៊ីតាលី, ផ្នែកព្រហ្មទណ្ឌ ទី១, សាលដីកា ថ្ងៃទី១២ មីនា ១៩៤៧, លេខ ២៧០, *បោះពុម្ពឡើងវិញនៅក្នុង* ទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៥, ២៣២, ខែមីនា ឆ្នាំ២០០៧ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ D'Ottavio] ។

អ្នកចូលរួមរូបនោះក៏ឆ្លើយចំពោះបទឧក្រិដ្ឋនោះដែរ ប្រសិនបើមានអង្គហេតុបង្ហាញថា វាគឺជាផលវិបាកដែលបានកើតចេញពីសកម្មភាព ឬការខកខានរបស់ខ្លួន"[54] ។

២៨. ដូចបានគូសបញ្ជាក់ដោយករណីរបស់ *Tadić* មានប្រជាជាតិជាច្រើន-ដែលរួមទាំងខាងប្រព័ន្ធច្បាប់អង់គ្លូ-អាមេរិកាំង ទាំងប្រពន្ធ័ច្បាប់ស៊ីវិលក្តី-គឺសុទ្ធតែគ្របដណ្តប់នូវទម្រង់ផ្សេងៗនៃការទទួលខុសត្រូវដែលមានលក្ខណៈស្រដៀងគ្នា នឹងសហកម្មឧក្រិដ្ឋកម្មរួមនេះ។ ឧទាហរណ៍ដូចជានៅប្រទេសបារាំង យ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ១៩៤៧ មកបានអនុវត្តនូវសញ្ញាណស្តីពី"សហចារីកម្ម" ដែលបានសម្រេចថា បើសិនជាមានជនណាម្នាក់ក្នុងចំណោមជនជាច្រើនបានចូលរួមនៅក្នុងផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួមណាមួយ បានប្រព្រឹត្តដោយផ្ទាល់ដៃនូវបទល្មើសណាមួយផ្សេងទៀតដែលស្ថិតនៅក្រៅពីផែនការឧក្រិដ្ឋកម្មរួម ក៏ប៉ុន្តែដែលអាចនឹងទាយទុកជាមុនបាន គឺជនទាំងអស់នោះត្រូវទទួលខុសត្រូវចំពោះបទល្មើសនោះ[55]។ ក៏ប៉ុន្តែ នៅក្នុងការពិនិត្យឡើងវិញរបស់ខ្លួនទៅលើប្រព័ន្ធនានានៅក្នុងតំបន់ដែលអនុវត្តនូវទម្រង់មួយចំនួននៃការទទួលខុសត្រូវទៅលើ "គោលបំណងរួម" នៅក្នុងករណីរបស់ *Tadić* បានសង្កត់ធ្ងន់ថា "ការយោងទៅលើច្បាប់ជាតិ និងទៅលើករណីយុត្តិសាស្ត្រ គឺវាគ្រាន់តែបម្រើដើម្បីបង្ហាញឱ្យឃើញថា សញ្ញាណនៃគោលបំណងរួមដែលបានប្រកាន់ខ្ជាប់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺមានមូលដ្ឋានគាំទ្រនៅក្នុងប្រព័ន្ធនៃច្បាប់ជាតិនានាជាច្រើន" តែប៉ុណ្ណោះតែមិនមែនដើម្បីគាំទ្រចំពោះការសម្រេចដែលថាទ្រឹស្តី គឺជាអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[56]។ នៅក្នុងករណីរបស់ *Milutinović* ដែលក្រោយមកត្រូវបានសម្រេចថាការទទួលស្គាល់នូវប្រភេទនៃការទទួលខុសត្រូវតាមបែបសហកម្មឧក្រិដ្ឋកម្មរួម គឺជួយគាំទ្រចំពោះការរកឃើញមួយថា ជនជាប់ចោទទទួលបានគ្រប់គ្រាន់នូវសេចក្តីជូនដំណឹងថា រូបគេអាចនឹងត្រូវកាត់ឱ្យជាប់ទោសក្រោមទម្រង់នៃការទទួលខុសត្រូវនេះ[57]។

---

[54] សេចក្តីសម្រេកលើករណីរបស់ D'Ottavio, ទំព័រទី ២៣៣ ។

[55] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៤ ។

[56] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៥ ។

[57] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៤១ ។

២៩. *នៅក្នុងករណីរបស់* Tadić បានរកឃើញថា មិនគ្រាន់តែសញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួម *ខ្លួនឯងផ្ទាល់* (*per se*) នោះតែប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺធាតុផ្សំនានាជាអត្តនោម័ត និងជាសត្យានុម័តរបស់សញ្ញាណនេះផងដែរ ដែលបានចូលជាផ្នែកមួយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអម្លុងពេលនៃជម្លោះនៅក្នុងប្រទេសយូហ្គោស្លាវី កាលពីដើមទសវត្សឆ្នាំ ១៩៩០ នោះ។ ញត្តិស្នើសុំនោះ បានលើកសំអាងថា នៅចន្លោះពេលរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងទសវត្សឆ្នាំ១៩៩០ គឺគ្មានការវិវឌ្ឍន៍អ្វីសំខាន់នោះទេនៅក្នុងផ្នែកយុត្តិសាស្ត្រ។ មានលិខិតុបករណ៍តែពីរគត់ប៉ុណ្ណោះ ដែលត្រូវបានលើកយកមកសំអាងនៅក្នុងញត្តិនោះ ដែលមានកាលបរិច្ឆេទក្រោយអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៅទៀតនោះគឺ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវអំពើភេរវកម្មបំផ្ទុះគ្រាប់បែក ហើយនិងលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅក្នុងលិខិតុបករណ៍នីមួយៗសុទ្ធតែមានចែងអំពីទម្រង់នៃការទទួលខុសត្រូវចំពោះ "គោលបំណងរួម"[58]។ ដោយសារតែករណីរបស់ *Tadić* នោះ សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានគេយកទៅអនុវត្តនៅក្នុងករណីនានាជាច្រើនទៀតនៅចំពោះមុខតុលាការ ICTY, ICTR, SCSL, និងនៅចំពោះមុខគណៈកម្មាធិការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានានៅប្រទេសទីម័រខាងកើត។

៣០. អាស្រ័យហេតុនេះ សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានចាក់គ្រឹះយ៉ាងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិតាំងពីមុនឆ្នាំ១៩៧៥មកម៉្លេះ ហើយបានស្ថិតនៅក្នុងសភាពបែបនេះដដែលរហូតមកទល់នឹងសព្វថ្ងៃនេះ។ លើសពីនេះ ដោយមាត្រា ២៩ នៃច្បាប់លក្ខន្តិកៈនៃតុលាការ *ដែលមានតែមួយគត់នេះ (this sui generic Court)* បានចែងអំពីវិធីទទួលខុសត្រូវផ្សេងៗតាមបែបរបស់ខ្លួនផ្ទាល់ ដែលសាយភាយចេញមកពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ គឺវាមិនចាំបាច់ទេ ផ្ទុយទៅនឹងអ្វីដែលបានលើកតវ៉ាជំទាស់នៅក្នុងញត្តិស្នើសុំ ដែលទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការក្រុងរបស់ប្រទេសកម្ពុជា បាន ឬក៏មិនបានក៏ដោយ [59]។

---

[58] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២១-៣ ។

[59] ញត្តិស្នើសុំ, ទំព័រទី ១ ។

*ការប្រព្រឹត្តិនូវសហកម្មឧក្រិដ្ឋកម្មរួមគឺមិនបំពានលើគោលការណ៍ស្តីពីនីត្យានុកូលភាពទេ*

៣១. ក្នុងញត្តិស្នើសុំនោះបានលើកឡើងជំទាស់ថា សហកម្មឧក្រិដ្ឋកម្មរួមមិនអាចយកមកអនុវត្ត នៅប្រទេសកម្ពុជានៅក្នុងយុត្តាធិការពេលវេលារបស់តុលាការនេះបានទេ ហើយថាការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងពេលបច្ចុប្បន្ននេះមុខជានឹងបំពានលើ *គោលការណ៍ស្តីពីមិនមានបទល្មើសទេបើគ្មានច្បាប់ចែង (nullem crimen sine lege)* ឬគោលការណ៍ស្តីពីនីត្យានុកូលភាពជាពុំខាន[60]។ សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត បដិសេធចោលនូវការលើកសំអាងខាងលើនេះ។

៣២. ច្បាប់ស្តីការបង្កើត អ.វ.ត.ក បានយកមាត្រា ១៥.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") មកដាក់បញ្ចូលដោយត្រង់ៗដែលក្នុងនោះចែងថា គ្មានជនណាម្នាក់ត្រូវបានកាត់ក្តីឱ្យមានទោសចំពោះអំពើ ឬការខកខានណាមួយដែលមិនបង្កើតទៅជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិណាមួយ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តនោះទេ។ ក៏ប៉ុន្តែ មាត្រា ១៥.២ បានចែងថា មិនត្រូវយក មាត្រា ១៥.១ នេះទៅបកស្រាយថា ជាការរាំងមិនឱ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌអន្តរជាតិនោះទេ៖ "គ្មានអ្វីនៅក្នុងមាត្រានេះដែលធ្វើឱ្យខូចដល់ការជំនុំជម្រះក្តី ឬដល់ការផ្តន្ទាទោសទៅលើជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយនៅក្នុងពេលអំពើនោះត្រូវបានប្រព្រឹត្ត ផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់ដែលមានការទទួលស្គាល់ពីសហគមន៍នៃប្រជាជាតិនានា ថាជាបទល្មើសព្រហ្មទណ្ឌ "។

៣៣. គោលការណ៍ស្តីពីនីត្យានុកូលភាព ជាសារវន្តវាគឺជា "គោលការណ៍នៃយុត្តិធម៌" មួយ[61] ។ គោលការណ៍នេះតម្រូវឱ្យទាំងបទល្មើស ទាំង*ទម្រង់នៃការទទួលខុសត្រូវ* ដែលបានចោទប្រកាន់ចំពោះចុងចោទនោះ ត្រូវតែមានអត្ថិភាព និងអាចទាយទុកជាមុនបាន នៅក្នុងពេលដែលចោទថា មានការប្រព្រឹត្តបទល្មើសទាំងនោះ។ អាស្រ័យហេតុនេះ ត្រូវតែបង្ហាញ

---

[60] ញត្តិស្នើសុំ , ទំព័រទី ១ ។

[61] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៧ ។

ភស្តុតាងឲ្យឃើញថា (i) បទល្មើសនោះបានកើតមានឡើង ដោយអនុលោមតាមច្បាប់របស់កម្ពុជា ឬមួយក៏ចាត់ទុកថា ជាបញ្ហាដែលទាក់ទងទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិមកទល់ត្រឹមឆ្នាំ១៩៧៥ ។ ហើយ (ii) ថា ចុងចោទទទួលបានគ្រប់គ្រាន់នូវសេចក្តីជូនដំណឹងថា ការចូលរួមរបស់ខ្លួននៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ មុខជានឹងតម្រូវឲ្យខ្លួនត្រូវទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌចំពោះអំពើទាំងឡាយដែលបានប្រព្រឹត្ត អនុលោមតាមសហកម្មឧក្រិដ្ឋកម្មរួម។

៣៤. ក្នុងការពិចារណាទៅលើគោលការណ៍ស្តីពីនីត្យានុកូលភាព តុលាការត្រូវតែបំពេញឲ្យបានគ្រប់លក្ខខណ្ឌថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលអាចអនុវត្តបាននោះ គឺវាគ្រប់គ្រាន់ដើម្បីអាចឲ្យទាយទុកជាមុនបាន និងថា ច្បាប់ដែលចែងអំពីរឿងនេះ គឺមានគ្រប់គ្រាន់សម្រាប់ឲ្យមានសិទ្ធិអាចពិនិត្យមើលបាននៅក្នុងពេលវេលាដែលពាក់ព័ន្ធគ្នានោះ[62]។ ទោះជាយ៉ាងណាក្តី នេះគឺមិនមែនជាការហាមឃាត់មិនឲ្យតុលាការនេះ "ធ្វើការបកស្រាយ ឬបញ្ជាក់ឲ្យបានច្បាស់អំពីធាតុផ្សំនានានៃបទល្មើសដោយឡែកណាមួយនោះទេ" ហើយក៏មិនបានរាំងមិនឲ្យច្បាប់មានការអភិវឌ្ឍន៍រីកចំរើននោះដែរ[63]។

៣៥. បុគ្គលម្នាក់អាចត្រូវបានគេចាត់ទុកថា ទទួលបាននូវការជូនដំណឹងគ្រប់គ្រាន់អំពីអំពើនានាដែលខ្លួនបានប្រព្រឹត្តដែលនឹងទាក់ទាញឲ្យខ្លួនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅតាមទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមនេះ គឺដោយផ្អែកលើការពិចារណាលើចំណុចដូចខាងក្រោមនេះ: (i) ប្រភេទ និងស្ថានទម្ងន់នៃអំពើឃោរឃៅព្រៃផ្សៃដែលបានប្រព្រឹត្ត។ និង (ii) លើអត្ថិភាពនៃសេចក្តីសម្រេចនានារបស់តុលាការ លិខិតុបករណ៍អន្តរជាតិផ្សេងៗព្រមទាំងច្បាប់ក្នុងស្រុកដែលក្នុងនោះមានការទទួលស្គាល់ចំពោះទម្រង់នៃការទទួលខុសត្រូវ ដែលមានលក្ខណៈស្រដៀងគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួម[64]។ កត្តាទាំងនេះប្រាកដជានឹងមានវត្តមាននៅក្នុងឧក្រិដ្ឋកម្មនីមួយៗនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទី១គឺ ឧក្រិដ្ឋកម្មទាំងនេះអាចត្រូវបានចាត់

---

[62] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៧ ។

[63] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៨ ។

[64] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៩-៤២។

ទុកថាជាការបំពានយ៉ាងធ្ងន់ធ្ងរដ៏ជាក់ស្តែងបំផុតទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលធ្លាប់បានឃើញនៅលើពិភពលោកតាំងពីសង្គ្រាមលោកលើកទី២មក[65]។ ទី២គឺ លិខិតុបករណ៍នានា និងសេចក្តីសម្រេចផ្សេងៗដែលកើតចេញពីការខិតខំប្រឹងប្រែងចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី២មក ដើម្បីកាត់ទោសចំពោះឧក្រិដ្ឋជនសង្គ្រាមនានា ទន្ទឹមគ្នាជាមួយនឹងការប្រើប្រាស់យ៉ាងទូលំទូលាយនូវការទទួលខុសត្រូវ តាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ទាំងនៅក្នុងប្រព័ន្ធច្បាប់អង់គ្លូ-អាមេរិកាំង និងទាំងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលជាការគ្រប់គ្រាន់សម្រាប់គាំទ្រចំពោះការរកឃើញថាចុងចោទទាំងឡាយដែលស្ថិតនៅចំពោះមុខតុលាការនេះ គឺសុទ្ធតែត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីថា ការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមណាមួយនោះមុខជានឹងតម្រូវឲ្យខ្លួនត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលខ្លួនបានប្រព្រឹត្តតាមទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួម ឬចាត់ទុកថាជាផលវិបាកដែលអាចទាយទុកជាមុនបានដោយសមហេតុសមផលនៃសហកម្មឧក្រិដ្ឋកម្មនោះ នៅក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥-១៩៧៩ ។

៣៦. ផ្ទុយពីអ្វីដែលញត្តិស្នើសុំនោះបានលើកជាសំអាង គឺវាគ្មានការពាក់ពន្ធ័នឹងការកំណត់សម្រេចក្នុងពេលបច្ចុប្បន្ននេះទេ អំពីថានៅពេលដែលឧក្រិដ្ឋកម្មផ្សេងៗត្រូវបានប្រព្រឹត្តនោះ តើសហកម្មឧក្រិដ្ឋកម្មរួមមានអត្ថិភាពនៅក្នុងយុត្តាធិការជាតិ (របស់ប្រទេសកម្ពុជា) ដែរឬទេ[66] ។ ដោយមិនគិតអំពីភាពដែលអាចទាយទុកជាមុនបាន និងអំពីសិទ្ធិអាចពិនិត្យមើលបាននៃសហកម្មឧក្រិដ្ឋកម្មរួមរបស់ចុងចោទ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គេអាចសន្និដ្ឋានពីអង្គហេតុបានថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ("ក្រមព្រហ្មទណ្ឌ") ជាទូទៅគឺបានគាំទ្រចំពោះទស្សនទានជាដើមអាទិ៍នៃសហកម្មឧក្រិដ្ឋកម្មរួម ។

៣៧. ក្នុងក្រមព្រហ្មទណ្ឌដែលស្ថិតជាធរមាននៅក្នុងអំឡុងពេលពីឆ្នាំ១៩៧៥-១៩៧៩ មានមាត្រាជាច្រើនដែលចែងពាក់ព័ន្ធទៅនឹងសេចក្តីតម្រូវមួយចំនួននៅក្នុងការទទួលខុសត្រូវជាក្រុម នោះគឺ: (១) ការរួមសកម្មភាពគ្នា (co-action)។ (២) ការសមគំនិតគ្នា (complicity)។ និង

[65] របាយការណ៍របស់ក្រុមអ្នកជំនាញការ អ.ស.ប, កថាខណ្ឌទី ១។

[66] សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៩ ។

(៣) ភាពជាអ្នកដើមគំនិតរួមគ្នា(co-aithorship)[67]។ ក្រមនេះបានបែងចែកបទល្មើសដែលមានការចូលរួមដោយចារីដែលមានចំនួនលើសពីម្នាក់ឡើងទៅ ជាពីរ(២) ប្រភេទគឺ: “ការរួមសកម្មភាពគ្នា” និង “ការសមគំនិតគ្នា”[68]។ ដើម្បីឱ្យមានលក្ខណៈសម្បត្តិជា “អ្នកដែលរួមសកម្មភាពគ្នា” (co-actor) បាននោះ គឺតម្រូវឱ្យជនជាប់ចោទណាម្នាក់បានចូលរួមដោយស្ម័គ្រចិត្ត និងដោយផ្ទាល់នៅក្នុងការប្រព្រឹត្តិបទល្មើស ។ ក្រមព្រហ្មទណ្ឌនេះបានចែងអំពីនិយមន័យនៃពាក្យ “ភាពជាអ្នកដើមគំនិតរួមគ្នា” នៅក្នុងបទព្រហ្មទណ្ឌ ។ ក្រមនេះបានចែងអំពីអត្ថិភាពនៃពហុភាពរបស់អ្នកដើមគំនិតនៅពេលដែលមានមនុស្សពីរ ឬច្រើននាក់ “ពិគ្រោះ ឬពិភាក្សាគ្នា” ស្តីពីការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយ[69]។ នៅពេលដែលសកម្មភាពរបស់ជនទី២បានឈានទៅដល់កម្រិតជួយជ្រោមជ្រែងឬជួយឧបត្ថម្ភគាំទ្រនោះ គឺជននោះត្រូវបានចាត់ទុកថាជា អ្នកសមគំនិតមួយរូបហើយ តែមិនមែនជាអ្នកដើមគំនិតរួមគ្នានោះទេ។

៣៨. អាស្រ័យហេតុនេះ សហកម្មឧក្រិដ្ឋកម្មរួម ជាវិធីមួយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងពេលឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ត្រូវបានប្រព្រឹត្តនោះ គឺជនត្រូវចោទនានាបានទទួលដំណឹងគ្រប់គ្រាន់អំពីការអាចទាយទុកជាមុនបាន និងអំពីសិទ្ធិអាចពិនិត្យមើលបាន ។

## ៤. សេចក្តីសន្និដ្ឋាន និង សំណើ

៣៩. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ញត្តិស្នើសុំខាងលើនេះមានកំហុសផ្នែកនីតិវិធី ព្រោះតែបានស្វែងរកដំណោះស្រាយដែលមិនសមស្រប និងដែលយ៉ាងហោចណាស់ក៏បានយកផ្នែកខ្លះមកប្រើឡើងវិញដោយការពិចារណានៅខាងក្រៅអង្គច្បាប់ដែរ។ ដោយផ្អែកត្រឹមតែលើហេតុផលតែប៉ុណ្ណោះ គឺញត្តិស្នើសុំនេះត្រូវតែប្រឈមទៅនឹងការបដិសេធចោល។ ញត្តិស្នើសុំនេះបានព្យាយាមក្នុងការធ្វើឱ្យដំណើរការរបស់តុលាការទៅជារឿងនយោបាយ ដោយការបង្កើតឡើងនូវអង្គហេតុ និងអង្គច្បាប់ផ្សេងៗ ដោយមិនបានធ្វើយុត្តិកម្មទេ ដែលធ្វើឱ្យមានការភ័យខ្លាច

---

[67] ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា ៨២, ១៤៥ ។ [*បន្ទាប់ពីនេះទៅហៅថា៖* ក្រមព្រហ្មទណ្ឌ] ។

[68] ក្រមព្រហ្មទណ្ឌ, មាត្រា ៨២។

[69] ក្រមព្រហ្មទណ្ឌ, មាត្រា ១៤៥។

អំពីការកាត់ទោសទៅលើមេដឹកនាំបច្ចុប្បន្នមួយចំនួន ដែលស្ថិតនៅក្នុងចំណោមឈ្មោះទាំងឡាយដែលបានលើកឡើងទាំងនេះ ប្រយោជន៍ដើម្បីធ្វើឱ្យសហចៅក្រមស៊ើបអង្កេត បាក់ទឹកចិត្តដោយប្រយោលមិនហ៊ានប្រើប្រាស់នូវវិធីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមួយ ដែលមានការទទួលស្គាល់ជាអន្តរជាតិនៅចំពោះមុខតុលាការនេះ។ សកម្មភាពបែបនេះ មានសក្តានុពលធ្វើឱ្យមានអស្ថេរភាពដល់ដំណើរការរបស់តុលាការ ដែលប្រជាជនកម្ពុជាព្រមទាំងសហគមន៍អន្តរជាតិបានទន្ទឹងរង់ចាំជាយូរណាស់មកហើយ។

៤០. ក្នុងជម្រើសមួយទៀត បើសិនជាញត្តិស្នើសុំនោះត្រូវបានពិចារណាថាអាចទទួលយកបានតាមទម្រង់នោះ សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត បដិសេធញត្តិស្នើសុំនោះ តាមការពិចារណាថាខ្លឹមសាររបស់សហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** — សហព្រះរាជអាជ្ញា

**លោក William SMITH** — សហព្រះរាជអាជ្ញារង